សារព័ត៌មាន ខ្មែរផុស ស.រ.អា
Free
KhmerPost USA
FREE BIWEEKLY CAMBODIAN ENGLISH NEWSPAPER SINCE 2007
978-677-7163 • VISIT KHMERPOST.US

MAYURA
Video . Fashion Jewelry . Hair Clips
978 998 0707 | 978 4558766
ផ្ញើរអីវ៉ាន់ទៅវិញទៅមកស្រុកខ្មែរ
ផ្ញើរតាមយន្តហោះ 1ផោន $11
ផ្ញើរតាមកប៉ាល់ 1ផោន $4
ធានាសងលុយវិញ បើសិនបាត់
21 branch St.
Lowell, MA 01851
Visit us on Facebook : MayuraLowell

## ព័ត៌មានសំខាន់ៗខាងក្នុង...

### មាហសន្និបាតពិភពលោករបស់លោក សម រង្ស៊ី...

*សូមអានទៅទំព័រទី ០២*



### ទស្សនាក្រុង"ញូយ៉ក"១ថ្ងៃចុងសប្តាហ៍...

*សូមអានទៅទំព័រទី ០៣*



### 2030 Marks Important Demographic...

*Please Read Page 06*




### កម្ពុជាដាក់ខ្លួនអោយនៅកណ្តាលភ្នក់ភ្លើង

*សូមអានទៅទំព័រទី ១០*



# វិចិត្រ ជុំ ត្រឡប់មកឡូវែលវិញជាមួយរឿង"គ្រីស្ទឹសនៅភែមបឺឡេ"

# A Review of Miss Bennet: Christmas at Pemberley

## A Play at the Merrimack Repertory Theatre



Katie Grindeland, Veronika Duerr, Vichet Chum, Amanda Collins, Alexis Bronkovic, Jesse Hinson, Victoria Grace, Shawn K. Jain

ដោយខ្មែរផុសស.រ.អា

វិចិត្រ ជុំ តារាងកនឹងជាអ្នកនិពន្ធដ៏កម្រមានដើមកំណើតខ្មែរបានត្រឡប់មកសម្តែងនៅឡូវែលវិញម្តងទៀត ក្នុងរយៈពេលបុណ្យដាច់ឆ្នាំ២០១៨ នារោងមហោស្រព "MRT"ជាមួយនឹងល្ខោននិយាយមួយដែលមានឈ្មោះថា "គ្រីស្ទឹសនៅភែមបឺឡេ" ។ ខុសស្រឡះពីអ្វីដែល វិចិត្រ បានសម្តែងពីឆ្នាំមុនពីរឿង"ខ្ញុំ"វិចិត្រ ដែលគូសវាសពីឆាកជីវិតខ្លួនឯង ជា ខ្មែរ នៅពេលមកដល់សហរដ្ឋប្រឈមមុខនឹងបញ្ហា ច្រើនជំពូក-មានរកការងារធ្វើមានបញ្ហាភាសាមាន បញ្ហាប្រកាន់ពូជសាស្ត្រ... ។ល ។ តែលើកនេះគឺជាខ្មែរម្នាក់សម្តែងរឿងអាមេរិកាំងជីវិតជាអភិជន តទៅទំព័រទី ០៨

Reviewed by Soben Pin | Photography by Megan Moore

This holiday season, I would like to applaud the Merrimack Repertory Theater its current play, Miss Bennet: Christmas at Pemberley which is an adaptation of Jane Austen's Pride and Prejudice.

Set in the early 1800s in England, the play has eight complex characters. I was pleasantly surprised to see the Cambodian American Continued to Page 08

មេធាវី លុយហាស្កែល
Law Office of Louis S. Haskell
Serving the Cambodian Community since 1987
PERSONAL INJURY របួសរាងកាយ
AUTO ACCIDENTS គ្រោះថ្នាក់ចរាចរ


978-459-8359
16 Pine Street - Lowell, MA | www.attorneyhaskell.com

ការិយាល័យ មេធាវី ថំមាស ស្តាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
• Immigration •អន្តោប្រវេសន៍
• Auto Crash •គ្រោះថ្នាក់រថយន្ត
• Divorce •លែងលះប្តីប្រពន្ធ
សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com

(នយោបាយកម្ពុជា)

# មហាសន្និបាតពិភពលោករបស់លោក សម រង្ស៊ី

ដោយ ពិន សំខុន

ស្របគ្នានឹងថ្ងៃប្រវត្តិសាស្ត្រ(បង្កើតរណសិរ្សរបស់គណបក្សប្រជាជន) លោក សម រង្ស៊ី បានធ្វើសន្និបាតពិភពលោកមួយនាថ្ងៃទី២ធ្នូ២០១៨ ដើម្បីប្រារព្ធពិធីតែងតាំងមួយ ដែលបណ្តាលឱ្យលោក សម រង្ស៊ី អតីតសហប្រធាននៃគណបក្សសង្គ្រោះជាតិក្លាយទៅជាប្រធានស្តីទីនៃគណបក្សដដែល បន្ទាប់ពីលោក កឹម សុខា ជាប្រធានកំពុងតែជាប់ក្នុងការឃុំឃាំងតាំងពីជាង១ឆ្នាំហើយ នៅពន្ធនាគារនឹងនៅគេហដ្ឋានរបស់លោក ឯទីក្រុងភ្នំពេញ ក្រោមការចោទប្រកាន់គ្មានភស្តុតាង នៃរបបលោក ហ៊ុន សែន។

មានសេចក្តីរាយការថា មនុស្សប្រមាណ៥០០នាក់ មកពីគ្រប់ទិសទីនៃពិភពលោក បានមកចូលរួមប្រជុំសន្និបាទនៅ"អាត់ឡង់តា"សហរដ្ឋ ដើម្បីរៀបចំក្បាលម៉ាស៊ីននយោបាយគណបក្សប្រឆាំងឡើងវិញ ហើយបានតែងតាំងលោក សម រង្ស៊ី ជា"ប្រធានស្តីទី"គណបក្សសង្គ្រោះជាតិឡើង ដែលមានអាណត្តិលោកមានរហូតដល់ លោក កឹម សុខា រួចចាកពីការឃុំឃាំង។ ការតែងតាំងក្បាលម៉ាស៊ីនគណបក្សនេះ ធ្វើឡើងសម្រាប់កាលៈទេសៈមួយ ដែលក្រុមគណបក្សប្រឆាំងមួយនេះ ត្រូវការឱ្យមានមេដឹកនាំម្នាក់ឱ្យមកដឹកនាំការប្រឆាំងនឹងរដ្ឋាភិបាលលោក ហ៊ុន សែន បើទោះជាលោក សម រង្ស៊ី បានដឹងថា យន្តការតែងតាំងនេះ ពុំស្របនឹងអត្ថន័យនៃលក្ខន្តិកៈគណបក្សសង្គ្រោះជាតិក៏ដោយ។ ក្រុមអ្នកចូលរួមសន្និបាត បានស្រែកជ័យឃោសជូនពរលោក សម រង្ស៊ី ហើយបង្ហាញពីការគាំទ្រដល់លោក កឹម សុខា ជាប្រធាននៅជាប់ក្នុងការឃុំឃាំង តែពុំមានវត្តមានកញ្ញា កឹម មនោវិទ្យា ជាសមាជិកសំខាន់ម្នាក់របស់គណបក្សនឹងជាកូនស្រីរបស់លោក កឹម សុខា ទេ។

នេះជាលើកដំបូងហើយ ដែលលោក សម រង្ស៊ី ផ្តើមប្រើចំឈ្មោះគណបក្សសង្គ្រោះជាតិឡើងវិញ ចាប់តាំងពីលាលែងពីដំណែងសហប្រធានកាលពីឆ្នាំ២០១៧មក ហើយស្របគ្នានឹងព្រឹត្តិការតែងតាំងនេះដែរ ក៏មានអ្នកគាំទ្រគណបក្សសង្គ្រោះជាតិនៅក្រៅប្រទេសជាច្រើនក្រុមនឹងច្រើនរយនាក់ទៀត មាននៅ"ឡូវែល"នៅ"ហ្វីឡាដែលហ្វៀ"នៅប្រទេសបារាំង ក៏បានចេញសេចក្តីថ្លែងការ ឆ្លើយតបប្រឆាំងនឹងការតែងតាំងថ្ងៃ២ធ្នូនៅ"អាត់ឡង់តា"នេះជាមួយគ្នា។ ក្រុមចុងក្រោយនេះមិនចង់ឃើញ CNRP រលាយដូចបំណងរបស់ ហ៊ុន សែន ទេ ពួកគេបានឱ្យដឹងថា "រហូតមកដល់ចុងឆ្នាំ២០១៧ ក្រុមអ្នកគាំទ្រគណបក្សសង្គ្រោះជាតិនៅក្រៅប្រទេសធ្លាប់មានការចុះសម្រុងគ្នាយ៉ាងរមួតធ្វើបាតុកម្មប្រឆាំងនឹងរបបហ៊ុន សែន ច្រើនដងជាមួយគ្នា, តែលោក សម រង្ស៊ី បានធ្វើការបំបែកបំបាក់ជាមួយនឹង"ចលនាសង្គ្រោះជាតិ"រួចមក"CNRP-A" រហូតដល់បានសម្រេចដោយសារចង់យកមុខមាត់ប្រាថ្នាទៅធ្វើការចរចាជាមួយភ្នំពេញតែម្នាក់ឯង"។ ក្រុមចុងក្រោយនេះ គឺជាក្រុម"ដងខ្លួន" សែសសល់របស់អ្នកគាំទ្រគណបក្សសង្គ្រោះជាតិនៅឯក្រៅប្រទេស បន្ទាប់ពី សម រង្ស៊ី កាត់ប្រមូលយកតែ"ក្បាល"ទៅបាត់, ក្រុម"ដងខ្លួន"គេចង់ឃើញ សម រង្ស៊ី ធ្វើការគាំទ្រកាងារជាមួយកញ្ញា កឹម មនោវិទ្យា-ញៀម ប៉ុញ្ញារិទ្ធ នាំគ្នាបញ្ចុះបញ្ចូលសហគមន៏អន្តរជាតិហើយដាក់ដង្ហៀបកុំឱ្យ ហ៊ុន សែន រីរួច ត្រឡប់ទៅរកអំណាចផ្តាច់ការវិញបាន-ប៉ុន្តែលោក សម រង្ស៊ី មិនអាចធ្វើបានទេ ដោយលោកយល់ឃើញថា អ្នកទាំងពីរមានបទពិសោធន៏"នៅខ្ចីពេក"។ មិនតែប៉ុណ្ណោះ ពួក"ដងខ្លួន"គេមានការសង្ស័យលើក្រុម"ក្បាល"ថា "ការចង់តែចរចារបស់ សម រង្ស៊ី នោះ អាចនឹងលាក់អាថិកំបាំងក្រខ្វក់ នាំគ្នាលក់ជាតិឱ្យសត្រូវ"ទៀតផង។


លោក សម រង្ស៊ី និងភរិយា នៅអាតាឡង់តា សហរដ្ឋអាមេរិក

**សកម្មភាពប្រតិកម្មរបស់លោក ហ៊ុន សែន**

រំពេចនោះដែរ លោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន បានថ្លែងជាសាធារណនៅភ្នំពេញ ដែលទំនងជាឆ្លើយតបនឹងមហាសន្និបាត"អាតឡងតា"ថា: ១-នឹងប្រគល់សិទ្ធនយោបាយឱ្យមន្ត្រីសង្គ្រោះជាតិ១១៨នាក់វិញ ២-អាចនឹងមានការដោះលែងអ្នកទោសនយោបាយដែលនៅសល់(អាចនឹងរាប់បញ្ចូលលោក កឹម សុខា ផងដែរ)

៣-ឱ្យអង្គការសិទ្ធមនុស្សនឹងអង្គការសារព័តិមានអន្តរជាតិដំណើរការឡើងវិញ... ។ល។ សកម្មភាពស្របគ្នារបស់លោក ហ៊ុន សែន ពេលនេះ អាចធ្វើឱ្យក្រុមលោក សម រង្ស៊ី អបអរបានខ្លះដែរ តែអត្ថន័យនេះ វាស្របនឹងប្រតិកម្មទៅកញ្ញា កឹម មនោ វិទ្យា ច្រើនជាង ដែលទាមទារឱ្យសហគមន៏អន្តរជាតិដាក់ដង្ហាបសេដ្ឋកិច្ច ដើម្បីឱ្យមានការប្តូរនយោបាយ នៅកម្ពុជាទៅវិញនោះទេ។

ប្រសិនបើការផ្លាស់ប្តូរនេះកើតឡើងមែននោះក៏មិនមានអ្វីចំណេញដល់ការទាមទាររបស់បក្សប្រឆាំងនៅឡើយនោះទេ ពីព្រោះទង្វើនេះ គឺដើម្បី "បំពេញចិត្ត"មហាអំណាចសេដ្ឋកិច្ចដែលកំពុងកាត់ជំនួយនៅកម្ពុជា ឯណោះទេ ហើយអំណាចផ្តាច់ ការក៏នៅពេញកណ្តាប់ដៃលោក ហ៊ុន សែន ដដែល ពុំអាចឱ្យក្រុមបក្សប្រឆាំងមានការបន្តវេដៃតវ៉ាបាននៅឡើយទេ ។ ការជម្រុញឱ្យមានការបែកបាក់ផ្ទៃក្នុងនៃគណបក្សប្រឆាំង គឺជារឿងគួរឱ្យអាម៉ាស់មិនគួរឱ្យនាំគ្នាទៅធ្លាក់ក្នុងអន្ទាក់ដីរាក់កំផែលរបស់ក្រុងភ្នំពេញទេ។


ដំណោះស្រាយការឱ្យខ្ចី
សម្រាប់លំនៅដ្ឋាន

តើលោក-អ្នកកំពុងរកទិញផ្ទះ ឬបង់សារជាថ្មីឡើងវិញនៅក្នុងរដ្ឋ Massachusetts ឬ New Hampshire ឬទេ? ក្រុមយើងដែលមានការដកពិសោធន៍នឹងណែនាំលោក-អ្នកឆ្លងកាត់ដំណើរការ ពីការស្វែងរក ជម្រើសការសុំខ្ចីប្រាក់រហូតដល់ដំណាក់ការបិទឯកសារចុងក្រោយបំផុត។ ការសម្រេចចិត្តដោយមិនបាច់ទៅណាឆ្ងាយផ្តល់ឱ្យយើងឆ្លើយតប និងផ្តល់ដំណោះស្រាយអោយបានឆាប់រហ័ស និងមានប្រសិទ្ធិភាព។

អង្គភាពឱ្យខ្ចីប្រាក់ទិញផ្ទះ
នៅធានាគារអេនធ័រប្រាយ្ស៍
978-656-5653 | 877-671-2265
ដាក់ពាក្យសុំតាមអនឡាញនៅ EnterpriseBanking.com/Mortgage



យើងមានកម្មវិធី និងសេវាកម្មដែលសមរម្យនឹងសេចក្តីត្រូវការខ្ចីប្រាក់ របស់លោក-អ្នក។

ការដាក់ពាក្យអនឡាញមានភាពងាយស្រួល!

Enterprise Bank
CREATE SUCCESS
Member FDIC
EQUAL HOUSING LENDER
EnterpriseBanking.com/Mortgage

# ទស្សនាក្រុង“ញូយ៉ក”១ថ្ងៃនាចុងឆ្នាំ២០១៨

ដោយ ពិន សំខុន

ខ្ញុំខានទៅលេងញូយ៉កយូរបន្តិចហើយ នៅឱកាសមានកូនស្រីធំមកពីស្រុកបារាំងមកលេងក្រុងញូយក៤ថ្ងៃ ក៏ឈៀងទៅកំសាន្តនៅទីនោះបានម្តងជាមួយគ្នា នាដើមខែធ្នូ២០១៨ នៅចំពេលដែលប្រជាពលរដ្ឋអាមេរិកាំងរៀបខ្លួនទទួលឆ្នាំថ្មី។

មែនជាទីក្រុងដ៏អ៊ូអរបំផុតនៅសហរដ្ឋអាមេរិកនេះ! ជាមួយនឹងអេដិន កូនប្រុសម្នាក់ទៀតអាយុ៨ឆ្នាំ យើងបាននាំគ្នាទៅឡើងជិះរថយន្តក្រុង នៅ“ឆាយណាថោន”នាក្រុងបូស្តុន គឺជាមធ្យោបាយធ្វើដំណើរដ៏មានតម្លៃថោកជាងគេបង្អស់ (ចំណាយតែ៨៥ដុល្លាប៉ុណ្ណោះ សម្រាប់ធ្វើដំណើរទៅមក ២នាក់ ពីបូស្តុន - ទៅញូយ៉ក) ដើម្បីចេញដំណើរនាម៉ោង៨រ្សៀ៥០នាទីរសៀល នៃថ្ងៃសុក្រ២០២៨នេះ សំដៅទៅទីក្រុងដ៏ធំបំផុតនោះតែ៤ម៉ោងប៉ុណ្ណោះក៏ដល់ញូយ៉កទៅហើយ។ ទេសចរក៏សម្បូរ - ជនជាតិភាគតិចក៏សម្បូរ - ម្ចាស់ស្រុកស្បែកសក៏មិនសូវសម្បូរនោះទេ -ហាងលក់ដូរទំនិញទំនើបក៏សម្បូរ -អ្នកលក់តាមចិញ្ចើមថ្នល់ក៏សម្បូរ -គឺជាទីក្រុងពាណិជ្ជកម្មដ៏ធំបំផុត មានកំណើតតាំងពីច្រើនរយឆ្នាំមកហើយ។ តាំងតែពី“អាគារទ្វីនត្ហាវ័រ-Twin tower”បានក្លាយជា“គ្រោនសេរ៉ូ Ground zero”ដោយសារតែបានត្រូវបំផ្លាញដោយភេរវករនាឆ្នាំ២០០១មក ខ្ញុំពុំដែលបានទៅដល់កន្លែងកើតហេតុនោះទេ ពីព្រោះតែការហាមឃាត់ នឹងដោយសារគេកំពុងតែសង់ឡើងវិញ តើឥឡូវជិត២០ឆ្នាំហើយ វាទៅជាយ៉ាងណាទៅវិញ?

ថ្ងៃទី១ខែធ្នូនេះ មេឃមិនសូវមានអំណោយផ្តល់ទេ ច្រើនតែងងឹតរកភ្លៀង តែមិនត្រជាក់ប៉ុន្មានទេ យើងផ្តើមស្រស់ស្រូបព្រឹកនៅ“ឆាយណាថោន Chinatown”ដ៏សម្បូរគុយទាវនឹងមីគាវឬមីសាច់ទា... ទីនោះកត់សំគាល់ដោយក្នុងហាងមានទាខ្វៃឬមាន់ស្ងោរក្បួរយើងរយោង, ដែលពោរពេញទៅដោយមនុស្សអ្នកទិញនឹងអ្នកលក់តថ្ងៃគ្នាលើទំនិញយ៉ាងវឹលវ៉ក់, ទៅដល់ទស្សនាទីនោះ ក៏ដូចជាបានទៅដល់ក្រុងចិនណាមួយនៃពីភពលោកដែរ, ចិនទាំងអ្នកក្រអ្នកមានចម្រុះដើរស្មើរជាន់ជើងគ្នា... មិនដូចជាស្រុកអាមេរិក ដែលគេរំពឹងគិតនោះទេ !

ចេញពី“ឆាយណាថោន”នាំគ្នាជិះ“មេត្រូ”គឺរទេះភ្លើងក្រោមដី រត់ខ្វាត់ខ្វែង ពិក្នុងជម្រៅដីនឹងក្រោមសមុទ្រ ពីចំណត“Grand station”សំដៅទៅចំណតក្រោមដី“Brooklyn Bridge Station”ដែលអាចប្រៀបប្រដូចមិនខុសអ្វីពីសម្បុកកណ្តៀរនោះទេ។ អេដេនឱទ្ទានថា“មេត្រូអាមេរិកមិនដូចមេត្រូនៅបារាំងទេ!” តទៅទំព័រទី ១៥


មេត្រូនៅញូយ៉ក


ទិដ្ឋភាពថ្មីនៅ“ក្រោណសេរ៉ូ”


ហាងវត្ថុអានុស្សាវរីយ៍ដ៏ច្រើន


## មកទេសចរណ៍រដូវស្លឹកឈើជ្រុះនៅតំបន់ម៉ារីម៉ាក់វ៉ាលេ

ក្រាន់តែធ្វើដំណើរតែកន្លះម៉ោងប៉ុណ្ណោះពីទិសពាយព្យនៃទីក្រុងប៊ូស្តុននឹងមកដល់តំបន់ម៉ារីម៉ាក់វ៉ាលេ។ការផ្លាស់ប្តូររដូវកាលបន្ថែមនៅភាពរស់រវើកនៅតំបន់នេះ។

មានថាមពលអស្ចារ្យដែលមិនអាចប្រកែកបាននៅតំបន់ ម៉ារីម៉ាក់វ៉ាលេ ដែលថាមពលដូចគ្នានេះដែលបានផ្តល់កំណើតដល់ប្រទេសរបស់យើង។ ក្រុងនិមួយក្នុងចំណោម ក្រុង និងទីប្រជុំជនទាំង 12 របស់យើងមានសម្រស់ និងទីកន្លែងប្លែកពីគេដែលលោកអ្នកត្រូវការ,

ដំណើរកម្សាន្តបន្ទាប់របស់លោកអ្នករង់ចាំលោកអ្នកនៅទី

















Greater Merrimack Valley
Convention & Visitors Bureau
adventuresawait
merrimackvalley.org

MASSACHUSETTS
massvacation.com

merrimackvalley.org

សូមចូលទៅកាន់ Twitter និង Instagram @MerrimackValley

# មណ្ឌលពិនិត្យសុខភាពលីន LYNN PRIMARY CARE CENTER

## វេជ្ជបណ្ឌិត សុខារិទ្ធិ ម៉ី DR. SOKHARITH MEY, MD

## (781) 780-7755








## មានទទួលអ្នកជំងឺថ្មី

**Now Accepting New Patients**

Family Medicine for Men, Women, and Children
Behavioral Health - Individual and Group Counseling
Evening & Weekend hrs available
We accept MassHealth, Medicare and other health insurances
Our staff speak Khmer

**280 Union St. Unit 402 Lynn, MA 01901**

ផ្នែកជំងឺទូទៅ សំរាប់បុរស ស្រ្តី និងកុមារ
ផ្នែកជំងឺផ្លូវចិត្ត ផ្តល់ប្រឹក្សាមួយទល់មួយនិងជាក្រុម
ក្រុមគ្រូពេទ្យមានបទពិសោធន៍ជាច្រើនឆ្នាំ
ធ្វើការបំរើសុខភាពក្នុងសហគមន៍ខ្មែរ ទីតាំងល្អនិងមានចំណតរថយន្ត
ឥតគិតថ្លៃ បើកពេលយប់ និងចុងសប្តាហ៍



MASSACHUSETTS HEALTH CONNECTOR for Business



ការផ្តល់ការធានារ៉ាប់រងសុខភាពមិនមែនជាការចំណាយទេ,
វាជាការវិនិយោគមួយនៅក្នុងក្រុមរបស់ខ្ញុំ។

"ហ៊ែលកូណិកទ័រ"សម្រាប់ពាណិជ្ជកម្ម
ផ្តល់នូវការគ្របដណ្តប់បុគ្គលិករបស់អ្នកសមនឹងទទួលបាន,
ក្នុងតម្លៃដែលអ្នកអាចទិញបាន។

- សងថ្លៃបំប៉នសុខភាពល្អ
- ឥណ្ឌទានពន្ធ
- មិនគិតថ្លៃបន្ថែម

សូមចូលមើលគេហទំព័ររបស់យើងសម្រាប់ជំនួយបន្ថែម: MAhealthconnector.org/middlesex



Boch Honda West
299 Littleton Rd, Westford, MA 01886
EXIT 32 - OFF 495
Happy Honda Days
SALES EVENT
HOME OF THE 20 YEAR 200,000 MILE LIMITED POWERTRAIN WARRANTY
BOCH Honda West
HONDA
ធ្វើដំណើរជុំវិញពិភពលោក 8 ដង
ហើយលោកអ្នក នៅតែមានការការពារ
រួមបញ្ចូលជាមួយនឹង
រាល់ការទិញរថយន្តហុងដា ថ្មី
ដោយមិនគិតថ្លៃបន្ថែមទៀតឡើយ!
ធានាមានរថយន្តថ្មីនៅក្នុងស្តុក លើកលែងតែម៉ូឌែលជាក់លាក់មួយចំនួនប៉ុណ្ណោះ
ហើយការធានាគឺមិនអាចធ្វើការផ្ទេរបានឡើយ។ មិនមានសម្រាប់រផ្លូល។
ច្បាប់ចម្លងលិខិតធានាមានសម្រាប់អតិថិជនមើលនៅកន្លែងលក់។
HONDA
មានវិញ្ញាបនបត្រផ្តល់សិទ្ធ ធ្វើជាម្ចាស់ជាមុន
ផ្តល់ជាពិសេសសម្រាប់ធ្វើជាម្ចាស់ជាមុន
2016 Honda ACCORD LX VIN: GA072518 $15,682
2016 Honda ACCORD LX VIN: GA185303 $16,477
2006 Mitsubishi ECLIPSE VIN: 6E014386 $5,995
2010 Toyota HIGHLANDER VIN: AS032165 $11,987
2016 Honda CIVIC EX VIN: GE205954 $16,994
2015 Honda ACCORD V6 COUPE VIN: FA009726 $16,998
2014 Honda ACCORD HYBRID TOURING VIN: EA011024 $12,912
2014 Mazda CX-9 GRAND TOURING VIN: E0428953 $16,499
2015 Honda CRV EX AWD VIN: FH698981 $18,995
2016 Honda CIVIC TOURING VIN: GE224073 $19,477
2010 Jeep WRANGLER 4DR VIN: AL216823 $17,931
2013 Audi S4 VIN: DA081730 $22,779
2015 Honda PILOT EX VIN: FB018561 $20,783
2017 Honda PILOT TOURING VIN: HB007847 $35,778
2016 Acura RDX AWD VIN: GL026906 $25,997
2015 BMW 640I XDRIVE CONVERTIBLE VIN: FD873174 $39,983
BochHondaWest.com
រាល់តម្លៃដែលបានផ្សព្វផ្សាយ មិនរួមបញ្ចូលពន្ធ និងការបង់ថ្លៃផ្សេងៗដល់រដ្ឋាភិបាល, ការចំណាយលើការរត់ការទទួលឥណទាន, ការបង់លើការរៀបចំឯកសារទិញលក់,
បង់ថ្លៃរៀបចំឯកសារបង់ពន្ធតាមប្រព័ន្ធអេលិចត្រូនិច និងការបង់ថ្លៃលើការធ្វើតេសការបំភាយឧស្ម័នរបស់រថយន្ត។ ការផ្តល់ជូននេះ ផុតកំណត់ថ្ងៃទី 19 ខែធ្នូ ឆ្នាំ 2018។
សម្រាប់ព័ត៌មានបន្ថែម
សូមទំនាក់ទំនង នីកូល ឈុន: nchhun@bochhondawest.com
ត្រូវការបុគ្គលិកផ្នែកលក់!
ទំនាក់ទំនងមកកាន់ ខេវិន រេជ: kcregg@bochhondawest.com
BochHondaWest.com | (978) 252-2125
HONDA

# 2030 Marks Important Demographic Milestones for U.S. Population
## Older People Projected to Outnumber Children for First Time in U.S. History

By KhmerPost USA

SEPT. 6, 2018 — The year 2030 marks an important demographic turning point in U.S. history according to the U.S. Census Bureau's 2017 National Population Projections. By 2030, all baby boomers will be older than age 65. This will expand the size of the older population so that 1 in every 5 residents will be retirement age.

"The aging of baby boomers means that within just a couple decades, older people are projected to outnumber children for the first time in U.S. history," said Jonathan Vespa, a demographer with the U.S. Census Bureau. "By 2035, there will be 78.0 million people 65 years and older compared to 76.7 million (previously 76.4 million) under the age of 18."




The 2030s are projected to be a transformative decade for the U.S. population. The population is expected to grow at a slower pace, age considerably and become more racially and ethnically diverse. Net international migration is projected to overtake natural increase in 2030 as the primary driver of population growth in the United States, another demographic first for the United States.

Although births are projected to be nearly four times larger than the level of net international migration in coming decades, a rising number of deaths will increasingly offset how much births are able to contribute to population growth. Between 2020 and 2050, the number of deaths is projected to rise substantially as the population ages and a significant share of the population, the baby boomers, age into older adulthood. As a result, the population will naturally grow very slowly, leaving net international migration to overtake natural increase as the leading cause of population growth, even as projected levels of migration remain relatively constant.

Other highlights:

Population Growth

By 2060, the United States is projected to grow by 79 million (previously 78 million) people, from about 326 million today to 404 million. The population is projected to cross the 400-million threshold in 2058.

In coming years, the rate at which the U.S. population grows is expected to slow down. The population is projected to grow by an average of 2.3 million people per year until 2030. But that number is expected to decline to an average of 1.9 million (previously 1.8 million) per year between 2030 and 2040, and continue falling to 1.6 million (previously 1.5 million) per year from 2040 to 2060.

Aging

As the population ages, the ratio of older adults to working-age adults, also known as the old-age dependency ratio, is projected to rise. By 2020, there will be about three-and-a-half working-age adults for every retirement-age person. By 2060, that ratio will fall to just two-and-a-half working-age adults for every retirement-age person.

The median age of the U.S. population is expected to grow from age 38 today to age 43 by 2060.









# DIVERSITY
## ADULT DAYCARE CENTER

*"A place where your loved ones can call home"*

**What is Adult Day Care:**
We understand that being a fulltime caregiver is a difficult job. When an elderly loved one needs additional care or supervision during the morning or day, it can create stress for the caregivers of the family. Many families think they have no choice but to quit their jobs or to admit their loved ones into a nursing home or assisted living facility. Diversity Adult Daycare Center (DADC) provides a safe supervised community where elderly adults can socialize, enjoy activities and get assistance with personal care. This will allow the caregivers of the family to have peace of mind when they have an appointment, work obligations or simply to enjoy some personal time.

**Benefits of Adult Day Care for Elderly Adults:**
Attending Adult Day Care has many positive benefits for elderly adults. Your loved ones do not have to be at home feeling lonely with no mental stimulation, when the caretakers are occupied. Being in an Adult Day Care creates a feeling of being in a community, where they can have fun and stay healthy with many activities. Your loved ones will look forward to having their independence and meeting their friends. Having friendships that you see every day promotes feelings of self-worth and camaraderie.

**Services we offer at DADC:**
- Nutritious meals and snacks
- Group fitness classes
- Education classes
- Group field trips and outings
- Fun daily entertainment and activities
- Assistance with personal care
- Salon service
- Transportation
- Monthly birthday parties
- Medical staff
- Gardening

**Who is an ideal candidate for Adult Day Care:**
- 55 years and older
- Southeast Asians & Hispanic
  (we are handicap accessible)

**Forms of payment that we accept:**
- We accept private pay
- All major insurances accepted

433 Elmwood Ave. Providence, R.I 02907
P: 401-427-1337 | F: 401-369-7818
www.diversityadc.com | diversityadc@gmail.com

**Se Habla Español**

We speak English, Spanish, Khmer, Lao, Hmong, Portuguese, Russian and Tagalog.
Come and schedule a free tour of our facility. We will provide free assessment and application assistance.
All major insurances and private pay accepted. Medicaid pays for adult day care, there is no cost to you.


Jesse Hinson, Alexis Bronkovic, Victoria Grace, Shawn K. Jain

តមកពីទំព័រទី ០១

## វិចិត្រ ជុំ ត្រឡប់មកឡូវែល...

នាជំនាន់មុនប្រកបដោយស្នេហាផ្អែមល្ហែមមានដួងចិត្តរីករាយនឹងប្រេះឆាលាយគ្នានឹងការយល់ច្រឡំគ្នាទៅវិញ ទៅមកផងនោះ ធ្វើឱ្យសាចរឿងទាក់អារម្មណ៏អ្នកមើលឱ្យព្រួយនឹងរីករាយច្របូកច្របល់គ្នា តាមដានស្ទើរមិនទាន់។

យើងបានទៅទស្សនារឿង"គ្រីស្ទឹសនៅភេមប៊ឺឡេ" នារសៀលដ៏ត្រជាក់ក្រោមសូន្យ នៃថ្ងៃសៅរ៍កន្លងទៅតែភ្ញៀវបានបកបំពេញកន្លែងអង្គុយគ្មានមានសល់ចន្លោះទេ កៅអីប្រមាណ៥០០កន្លែងបានលក់អស់មនុស្សភាគច្រើនជាមនុស្សចំណាស់ តែមិនសូវមានខ្មែរមកមើលនៅឡើយទេ។ តួរសម្តែងប្រកបដោយទេពកោសល្យប្រមាណ១០នាក់ សម្តែងក្រោមពន្លឺភ្លើងផ្លាស់ប្តូរតាមពេលនឹងកន្លែងសម្លេងនិយាយឬភ្លេងព្ចច្បាស់មិនថា តទៅទំព័រទី ០៩


Shawn K. Jain, Vichet Chum, Jesse Hinson

Continued from page 01

## A Review of Miss Bennet: Christmas...

actor/playwright Vichet Chum with one of the lead roles. He plays English Lord Arthur de Bourgh, a wealthy scholar who longs for a perfect wife and love.

Unlike many Hollywood films which often include an Asian American character in a minor, stereotyped role, the Merrimack Repertory Theatre put Vichet Chum at center stage and he once again won the admiration of the audience as he did in last year's "Knyum" a story of discovering his own roots — a one man show he wrote and starred in.

This play features a Christmas celebration at Pemberley, Mr. Darcy's residence. All four daughters of Mr. Bennet gather to celebrate Christmas and the visit of the wealthy English Lord Arthur De Bough (Vichet Chum). The story focuses on the importance of marrying well but also of marrying for love which is what Lord de Bourgh does when he falls in love with Miss Bennet who shared his passion for learning.

My natural curiosity had me wondering after the show about casting Vichet Chum as a prime character in this play? So I reached out Sean Daniel, the Artistic Director of the MRT who explained:

"It's part of the New MRT to be dedicated to reflecting the community we live with on stage. Lowell is a progressive city of the future and you should see that when you attend the theater. But it's easy with Vichet," Sean adds "as he's just the best actor for the role. We looked at lots of people and none had the comedic chops with the heart that he does".

I couldn't agree more with Sean. Vichet merited this role, not only because he's Cambodian American, but because he is an extraordinary actor himself. In 2018, was the Princess Grace Award recipient in Playwriting. He is also a proud graduate of the University of Evansville (BFA) and Brown University/Trinity Repertory Company (MFA).

I asked Sean what it was like to work with Vichet in this play which is based on a classical novel with all white characters.

Sean pointed out that "Bingley [another major character] is played by an Indian actor - and once again, it's just because I find few actors in the world funnier than Shawn!".

He added "I do know that often, at most other theaters, these actors aren't given the types of roles that

Continued to Page 09

តមកពីទំព័រទី ០៨

## វិចិត្រ ជុំ ត្រឡប់មកឡូវែល...

អង្គុយជិតឬឆ្ងាយទេ ឆាកសម្តែង គឺរៀបបន្ទប់ទទួលភ្ញៀវមានលក្ខណជាបណ្ណាល័យដ៏ធំមួយ ដែល គេឃើញនៅតាមបង្អួចមានព្រឹលធ្លាក់នៅខាងក្រៅផង -ក្នុងបរិវេណនោះ ស្រ្តីជាបងប្អូន"បេណេត"បង្ហាញពីទឹកដមនៃជីវិតពេញវ័យក្រមុំក្នុងគ្រួសារនៅពេល


Amanda Collins, Vichet Chum

ចង់រកគូរស្រករ នាឱកាសមុនចូលឆ្នាំថ្មី។ សាច់រឿងផ្តើមលំបាកយល់ជាច្របូកច្របល់នៅពេលកម្លោះ "អាកទ័រ ដឺបួគិ" (សម្តែងដោយ វិចិត្រ ជុំ) ចូលមកដល់ ហើយចាប់ចិត្តលើកញ្ញា ម៉ារី ប៉ុន្តែ កម្លោះនោះក៏ជាអ្នកមានគូរដណ្តឹងរួចទៅហើយទៀត តើគេរំដោះខ្លួន-របៀបណា?

វិចិត្រ ជុំ ជាសិល្បករល្ខោននិយាយដែលកំពុងតែជោគជ័យ គេរស់នៅ"យូស្តុន" នៃរដ្ឋ"តិចសាស់" រៀនមុខវិជ្ជាសិល្បៈ នឹងសរសេររឿង ដែលមានក្រុមគ្រួសារជួយជ្រោមជ្រែងពេញទំហឹង ដល់បន្ទាប់មកក៏បានមករស់នៅប្រកបមុខរបរជាសិល្បករ ឯកទេសនៅញូយ៉កវិញ ដែលទីនោះ ជាកន្លែងស្រួលរកការងារសម្តែងប្រសើរបាន។ មានកូនខ្មែរតិចតួចណាស់ ដែលបានជ្រើសយកមុខវិជ្ជានេះ ហើយការមកដល់របស់ វិចិត្រ ជុំ នៅឡូវែលនេះ រាប់បានថាជាសំណាងមួយដល់អ្នកក្រុងឡូវែល ដែលបានឃើញគំរូសិល្បៈករ វិចិត្រ ក៏អាចជាអ្នកបណ្តុះផ្ចាលដល់អ្នកជំនាន់ក្រោយនៅឡូវែលបានដែរ។

Continued from page 01

## A Review of Miss Bennet: Christmas...

usually go to white men, but MRT is working to be a leader in equity, diversity and inclusion and all of that


Victoria Grace, Katie Grindeland, Amanda Collins, Alexis Bronkovic

starts with who we put on our stage."

I commend Sean Daniels and his entire team at the Merrimack Repertory Theatre for their commitment to presenting excellent plays with diverse casts. To do so with a very complex, classic piece of work like Jane Austen's Pride and Prejudice is great evidence that the MRT succeeds with this approach. They have demonstrated that you can have equity,diversity and inclusion without diminishing the quality of the theatre.

Miss Bennet: Christmas at Pemberley is a wonderful romantic comedy with colorful holiday costumes and outrageously funny situations. The 2.5 hour play will fill your heart with holiday joy and your head with admiration for the loveliness of the characters who were flawless in their performances and the talent of the diverse cast. - The Khmer-Post USA



# កម្ពុជាដាក់ខ្លួនឱ្យនៅកណ្ដាលភ្នក់ភ្លើងសង្គ្រាមត្រជាក់ (ត)

ដោយ ពិន សំខុន

បន្ទាប់ពីបោះឆ្នោតនៅកម្ពុជា ដែលសហគមន៍អន្តរជាតិចាត់ទុកថាជាការបោះ ឆ្នោតខុសច្បាប់ រួចមកប្រទេសកម្ពុជាក៏បានទទួលជំនួយ នឹងប្រាក់កម្ចីជាច្រើនសន្ធឹកសន្ធាប់ពីប្រទេសចិន ហើយរក្សាកម្ពុជាជាមហាសម្ពន្ធមិត្តក្នុងការប្រឈមមុខនឹងទណ្ឌកម្មសេដ្ឋកិច្ច ដែលសហគមន៍អឺរ៉ុប នឹងអាមេរិក បានដាក់សម្ពាតមកលើកម្ពុជានឹងទណ្ឌកម្មទៅលើបុគ្គលដែលបានផ្ដើមទៅលើមន្ត្រីយោធាជាន់ខ្ពស់របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។ ទណ្ឌកម្មលើបុគ្គលនោះនឹងរីករាលដាលចល់មន្ទីឯទៀតៗ នៅពេលមិនយូរនាខាងមុខដែលទំនងជាមានការប៉ះពាល់ដល់គ្រួសារលោកនាយករដ្ឋមន្ត្រី នឹងរូបលោក ហ៊ុន សែន ខ្លួនឯងទៀតផង។

លោកអនុប្រធានាធិបតីសហរដ្ឋអាមេរិក ម៉ាយ ផិន នៅពេលថ្លែងសម្ដែងការព្រួយបារម្ភ ដែលកម្ពុជាបានរំកិលខ្លួន ទៅនៅចំកណ្ដាលនៃការប្រទុស្ដរាយនឹងប្រឈមមុខនៃកូសត្រូវប្រយុទ្ធគ្នារបស់ សហរដ្ឋអាមេរិក គឺសំដៅទៅលើភូមិសាស្ត្រដែលយោធាចិនកំពុងតែរីកដុះដាលយ៉ាងលឿនពីសមុទ្រចិនខាងត្បូង រហូតដល់សមុទ្រឥណ្ឌា ហើយគម្រាមកំហែងដល់សន្តិភាពប្រទេសអាស៊ីទាំងមូលទៀតផង។ ក្នុងឱកាសប្រជុំ "អេផិក"នោះ លោក ម៉ាយ ផេន បានឆ្លៀតឱកាសពង្រឹងមិត្តភាពជាមួយប្រទេសអាស៊ីអគ្នេយ៍នៅពេលដែលទំនាក់ទំនងនយោបាយនៅកម្ពុជា កំពុងតែត្រូវថមថយជាខ្លាំងជាមួយនឹងសហរដ្ឋអាមេរិក (ដូចជានៅឆ្នាំ២០១៧ កម្ពុជាបានលប់ចោលសមយុទ្ធជាមួយយោធាអាមេរិកាំង -មានការបណ្ដេញបុគ្គលិកការបរទេសអាមេរិកាំង ដែលវិជ្ជាស្ថានជាតិប្រជាធិបតេយ្យអាមេរិកាំងជាអ្នកផ្គត់ផ្គង់ថវិការ)។ មិនតែប៉ុណ្ណោះ



ចំណុចដែលមានកំពុងផែរបស់ចិនសង់នៅតាមសមុទ្រអាស៊ី

កម្ពុចាបានបន្ថែមរឹតចំណងសហប្រតិបត្តិការ ជាមួយសមយុទ្ធយោធាចិន នាឆ្នាំបន្ទាប់ ដែលមានឈ្មោះថា "សមយុទ្ធនាគមាស"ទៀតផង។

ធ្វើយ៉ាងនេះ ហ៊ុន សែន អនុញ្ញាត្តិឱ្មចិនលុកដៃក្នុងសេដ្ឋកិច្ច នយោបាយ នឹងយោធាបាន, គឺជាការស្វែងរកកិច្ចគាំទ្រពេញទំហឹងពីចិន ចំពោះការដាក់គំនាបសេដ្ឋកិច្ចផង នឹងសុំឱ្យចិនជួយការពារមន្ត្រីរបស់ខ្លួន ដែលរងការដាក់ឬណ្ឌកម្មសេដ្ឋកិចពីសហរដ្ឋអាមេរិកផង នឹងពីសហគមន៍អឺរ៉ុបផង រហូតដល់ចំណុចមួយដែលដែលមិនដឹងថាចំណុចក្រហម បានឆ្លងផុតទៅហើយ ឬក៏អត់នោះទេ... ចំនុចក្រហមនោះគឺបូរណភាពរបស់កម្ពុជាបច្ចុប្បន្ន ប្រៀបប្រដូចទៅនឹងដំណើរទៅរក"អនានិគមនាឆ្នាំ១៨៦៣"នៅពេលដែលបារាំងបានមកដល់ដែនដីឥណ្ឌូចិនដូច្នោះដែរ។

សម រង្ស៊ី អតីតប្រធានគណបក្សសង្គ្រោះជាតិ ពាននិយាយប្រាប់"អេស៊ីយាថាម"ថា ការដែលរដ្ឋាភិបាលខ្មែរអនុញ្ញាត្តិឱ្យយោធាចិនសង់សំណង់អ្វីមួយនៅលើទឹកដីខ្មែរ គឺជាការរំលោភលើសន្ធិសញ្ញាក្រុងប៉ារីសឆ្នាំ១៩៩១ យ៉ាងជាក់ស្ដែង, លោកបានបន្តថា នៅពេលដែលកម្ពុជាបោះបង់អព្យាក្រឹត្យភាពរបស់ខ្លួន ហើយក្លាយទៅជាផ្នែកណាមួយនៃការបង្ករគម្រាមកម្ហែងដល់ប្រទេសជិតខាងនោះ គឺ ហ៊ុន សែន កំពុងតែលេងជាមួយនឹងភ្លើង ហើយមិនគ្រាន់តែបំផ្លាញលទ្ធិប្រជាធិបតេយ្យនៃប្រទេសតែប៉ុណ្ណោះទេ ថែមទាំងបោះបង់សន្តិភាពនៅក្នុងតំបន់ផង..."។

អ្នកវិភាគយុទ្ធសាស្ត្រនិយាយថា នៅពេលដែលចិនផ្ដើមបង្កើតកំពុងផែខ្លួនមួយដំបូងនៅ"យីប៊ូទី" គេក៏យល់ភ្លាមថាចិននឹងប្រើប្រព័ន្ធយោធាតាមសមុទ្រចាប់តាំងពីសមុទ្រចិនខាងត្បូង ដើម្បីកាពារដែនសមុទ្រតាមជ្រោយម៉ាឡាកាបន្ថែមទៀតជាមិនខានដូច្នេះហើយ នឹងមានកំពុងផែជាច្រើនទៀតនឹងដុស-ដូចផ្សិត... តើហេតុអ្វីក៏ចិនសង់កំពុងផែនៅកម្ពុជា (កោះកុង) ដែលនៅសមុទ្រក្នុងទៅវិញ? គេថា នៅពេលមានទំនាស់តឹងតែងរវាង ចិន-អាមេរិកាំង គឺចិនចង់បង្វែរអារម្មណ៍វៀតណាម ដែលចងទំនាក់ទំនងជាមួយអាមេរិកាំងនៅ"កាំរ៉ាញ់"ឱ្យងាកមកខាងលិចឱ្យបានច្រើន ដើម្បីបើកចំហរសមុទ្រចិននៅខាងកើត...។ សកម្មភាពឆ្លៀតឱកាសរបៀបនេះនឹងកើតជាបន្តរទៅទៀត ដ៏រាបណា"លំនឹងខាងលិចនឹងខាងកើត" បានត្រូវសង្កោះសង្កើ បានន័យថា នាប៉ុន្មានឆ្នាំចុងក្រោយនេះ សម្ព័ន្ធមិត្តខាងលិចបានដកខ្លួនថយទុកឱ្យកម្លាំងប្រទេសកុម្មុយនិស្តដូចជាចិននឹងរុស្សីធ្វើសកម្មភាពដាក់សម្ពាធស្ទើរគ្រប់កន្លែងក្នុងពិភពលោក។ នៅកម្ពុជា នៅឡាវ ដោយសារ"គ្មានលំនឹងខាងលិចខាងកើត" វៀតណាមបន្ទាប់មកចិន បានប្រើសម្ពាតយោធា-សេដ្ឋកិច្ច នេះមកលើរដ្ឋអំណាចដែលគ្មានការគ្រប់គ្រងរឹងមាំបណ្ដាលឱ្យប្រទេសទាំងមូលធ្លាក់ជារណបប្រទេសខ្លាំងចៀសមិនរួចឡើយ។







# អតីតបវរកញ្ញាអាយុ ៥៨ បានវិលត្រឡប់មករកការសិក្សា ដោយជោគជ័យនៅសាលាម៉ិឌូលស៊ិច ខាំញ៉ូនីធី ខលលេច

ដោយ សុខារ័ត្ន កួយ

លោកស្រី ហ្វិនសីស ដេសាវ្វ (Frances DeSalvio) អតីតបវរកញ្ញា អាតាលិនតិច ស៊ីធី ក្នុងកំឡុងឆ្នាំ ១៩៨១ និង ញ៉ូ ជឺរស៊ី ក្នុងកំឡុងឆ្នាំ១៩៨៥ បាន កំពុងតែស្វែងរកបំពេញសេចក្តីស្រមៃរបស់លោកស្រី ដោយបានធ្វើដំណើរដោយរថយន្ត មីនី ខុបភ័រ ពណ៌ក្រហមមកកាល់ការិយាល័យរដ្ឋបាលរបស់សាលាម៉ិឌូលស៊ិច ខាំញ៉ូនីធី ខលលេចដើម្បីចុះឈ្មោះសិក្សា ដោយសង្ឃឹមថា មិនទាន់យឺតពេលនោះទេកាលពីពីរឆ្នាំមុន ។

កាលពីឧសភា លោកស្រី ដេសាវ្វ បានបញ្ចប់ថ្នាក់បរិញ្ញាបត្ររងដោយចាប់យកជំនាញ Liberal Arts & Sciences ។ លោកស្រីកត់សម្គាល់ឃើញថា ការទទួលបានសញ្ញាប័ត្របរិញ្ញា គឺជាជោគជ័យដ៏យូរអង្វែង ។ដោយសារតែមូលហេតុនេះ នៅរដូវឈើជ្រុះស្លឹកនេះលោកស្រីបានធ្វើដំណើរទៅកាន់មហាវិទ្យាល័យ ខាមប្រិច ដើម្បីបន្តការសិក្សារបស់លោកស្រីដោយចាប់យកជំនាញផ្នែកចិត្តសាស្ត្រ ។

ផ្លូវនៃការសិក្សារបស់លោកស្រី ដេសាវ្វ ទៅមហាវិទ្យាល័យមិនមែនរឿងធម្មតានោះទេ ។ ការសិក្សារបស់លោកស្រី ត្រូវបានញ៉ាំញីដោយពន្លឺភ្លើង និងការរំភើបនៃទីក្រុងអាត្លង់ទិច រដ្ឋញ៉ូជស៊ី ។ លោកស្រីចូលចិត្តអាជីពដែលអ្នកឈ្នះជ័យលាភីបវរកញ្ញាសម្រស់ និងជាតារាម៉ូឌែល ហើយបន្ទាប់មកជាច្រើនទសវត្សរ៍បានក្លាយជាម្តាយដែលស្រលាញ់កូនចំនួន ៤នាក់ ។

នៅក្នុងឆ្នាំ ១៩៧៨ លោកស្រីបានបញ្ចប់នៅថ្នាក់វិទ្យាល័យ ហើយមិនបានប្រកដចំពោះអនាគតរបស់ខ្លួននោះទេ។ លោកស្រីមានប្រសាសន៍ថា ម្តាយលោកស្រី មិនមានធន់ធានដើម្បីបញ្ជូនលោកស្រីបន្តការសិក្សាថ្នាក់មហាវិទ្យាល័យ ។ "ម្តាយលោកស្រីមិនដឹងពីវិធីក្នុងការប្រើប្រាស់ប្រព័ន្ធដើម្បីកាក់ពាក្យស្នើរសុំជំនួយហិរញ្ញវត្ថុក្នុងការសិក្សានោះទេ" ។

លោកស្រីត្រូវបង្ខំចិត្តធ្វើការនៅកាស៊ីណូដែលបានបង្កើតដំបូងបង្អស់មួយនៅតំបន់ឆ្នេរភាគខាងលិចមួយដែលមានឈ្មោះ រីសថ អ៊ីនធ័រណាសិនណលជាអ្នកបំរើការ និងសម្តែង ។ នៅកំពុងពេលបំរើការងារលោកស្រីបានធ្វើវិសមកាលចំនួន៦សប្តាហ៍ទៅកាន់អាស៊ីដូចជា តៃវ៉ាន, ជប៉ុន, និងក្រុងបាងកកជាមួយនិងក្រុមនារីស្លាក់ម៉ៃយោហែលទឹកកាតាលីណា ។ ពេលលោកស្រីត្រឡបមកវិញ បានទទួលការហៅទូរស័ព្ទពីនាយកប្រតិបត្តិកាស៊ីណូម្នាក់ដោយសុំឱ្យនាងណាត់ជួបគ្នា ។ ប្រាំមួយសប្តាហ៍ក្រោយមក លោកហ្វិនសីស ខេប (Francine Knapp) និងលោកស្រី ប៉ប ដេសាវ្វ (Bob DeSalvio) បានភ្ជាប់ពាក្យ ហើយបានរៀបការនៅខែកញ្ញា ឆ្នាំ១៩៨៦ ។

បន្ទាប់ពីរៀបការ លោកស្រីបានទទួលចំណងដៃកូនចំនួនបួននាក់ ហើយដើរតួនាទីជាម្តាយនៅផ្ទះ។ ដោយកូនៗរបស់លោកស្រីធំដឹងក្តី លោកស្រីបានមានពេលវេលា និងធនធានដើម្បីផ្តោតលើការសិក្សា។ បន្ទាប់ពីបានសិក្សានៅវគ្គរដូវក្តៅបានមួយចំនួននៅសាលាម៉ិឌូលស៊ិច ខាំញ៉ូនីធី លោកស្រីមានអារម្មណ៍ធូរស្រាល និងមានទំនុកចិត្តគ្រប់គ្រាន់ក្នុងការចុះឈ្មោះចូលរៀនចំនួនប្រាំថ្នាក់នៅរដូវស្លឹកឈើជ្រុះឆ្នាំ ២០១៦ ។

ក្នុងពេលសិក្សា លោកស្រីមានការលំបាក ដោយសារបច្ចេកវិទ្យាទាំងអស់ដែលគ្រូបង្រៀនរបស់លោកស្រីប្រើក្នុងថ្នាក់ គឺច្រើនពេក។ ក្នុងកំឡុងពេលនោះលោកស្រីបានត្រៀមខ្លួនបោះបង់ការសិក្សា។ ប៉ុន្តែអ្នកគ្រូភាសាអង់គ្លេស លោកស្រី ឡូសា សាលាឌីណូខូល មិនបានដឹងពីការដែលលោកស្រីចង់បោះបង់ការសិក្សានោះទេ។ អ្នកគ្រូ ខូល បានប្រាប់លោកស្រីថា ដរាបណាលោកស្រីធ្វើការងារសាលាដែលបានដាក់ឱ្យអ្នកគ្រូនឹងជួយលោកស្រីក្នុងការប្រើប្រាស់បច្ចេកវិទ្យា។ ចុងក្រោយនោះគឺលោកស្រីបានធ្វើការងារសាលា និងមានការជួយពីអ្នកគ្រូភាសាដោយទទួលបានជោគជ័យ ។ លោកស្រីដេសាវ្វ បានមានប្រសាសន៍ថា "ថ្មីៗនេះប្តីរបស់ខ្ញុំបានសួរខ្ញុំថា តើមានអ្វីកើតឡើងនៅទីនេះ? ខ្ញុំមានអាយុ៦២ឆ្នាំ អ្នកមានអាយុ៥៨ឆ្នាំ ហើយ ខ្ញុំត្រៀមខ្លួនរួចរាល់ហើយ។ តើអ្នកនឹងទៅធ្វើការទេឥឡូវវីរ? លោកស្រីបានបន្តថា "ខ្ញុំបានប្រាប់គាត់ថា ខ្ញុំមិនទាន់ប្រកត់នៅឡើយនោះទេ" ។ "ខ្ញុំនឹងស្តាប់, បើកចិត្តឱ្យទូលាយ ហើយតែងតែសម្លឹងមើលទៅអនាគតជានិច្ច" ។





បវរកញ្ញា ញ៉ូជឺស៊ីឆ្នាំ១៩៨៥

# Former Beauty Queen Returned to Earn a Degree at MCC

By KhmerPost usa

Two years ago, Frances DeSalvio, a former Miss New Jersey turned empty nester, was looking to fulfill a dream. She hopped into her little red Mini Cooper and headed to the Middlesex Community College admissions office, hoping it wasn't too late.

Last May, DeSalvio graduated with an associate degree in Liberal Arts & Sciences and checked off a long-coveted accomplishment: Earning a college degree.

"I feel very much complete, much more of a whole person than I was before, and I have Middlesex to thank for that," said the Lexington resident. "Having an education, any kind of education – a trade, a skill, a course of study – completes a person in a certain way."

It's not too late to finish your degree at MCC. Registration is now open for Wintersession, a condensed, three-week session offered during the break between fall and spring semesters. Wintersession classes run Jan. 2-18, 2019, on the Bedford campus or online. Call 1-800-818-3434 to enroll.

DeSalvio's path to college was not traditional. Her education was detoured by the bright lights and excitement of Atlantic City, N.J., at its peak. She enjoyed a whirlwind career as a beauty pageant winner and model, and then decades as a doting mom.

In the summer of 1978, as the first casinos were opening in Atlantic City, DeSalvio (then Francine Knapp), had graduated from high school, but was unsure of her future. "My parents didn't have the resources to send me to college," she said. "Financial aid wasn't as accessible then, and my parents didn't know how to navigate the system."

She landed a job with Resorts International, the first casino on the East Coast, working as a hostess, and performing in reviews and shows. In 1981, DeSalvio was crowned Miss Atlantic City. In December 1984, she beat out 93 other contestants to become Miss New Jersey 1985.

That fall, she headed to Asia for a six-week tour of Taiwan, Tokyo and Bangkok with Catalina swimwear. When she returned home, DeSalvio received a phone call from a casino executive asking her out on a blind date. Six weeks later, Francine Knapp and Bob DeSalvio were engaged. They married in September 1986.

The DeSalvios had four children and Frances assumed the role of stay-at-home mom. Four years ago, her husband took a job as president of the Wynn Boston Harbor Casino (now the Encore Boston Harbor, under construction in Everett), and the couple moved to Lexington.

With her children grown, DeSalvio had the time and resources to focus on her education. After taking a couple of summer courses at MCC, she was feeling comfortable and confident enough to sign up for five classes in fall 2016.

"Then I had a meltdown." All the technology her professors were utilizing in class was too much. DeSalvio was ready to dropout. But her English professor, Louisa Saladino-Kuhl, wouldn't hear of it. "She told me, 'As long as you put in the work, I'll help you with the technology,' and she did."

This fall, DeSalvio headed to Cambridge College in Boston to continue her education and study psychology. "My husband recently asked me, 'What is going on here? I'm 62, you're 58, I'm getting ready to finish. Are you going to go to work now?'

"I told him I'm not really sure," said DeSalvio. "I'm going to listen, be open-minded and always look to the future."

KhmerPost USA, LLC
សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក

អគ្គនាយក សុបិន្ត ពិន

Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
sobenpin@khmerpost.us

អ្នកនិពន្ធ ខ្មែរ Khmer Editorial

និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
(978-942-1641| rogerpin@khmerpost.us

ផ្សាយពាណិជ្ជកម្ម សុបិន្ត ពិន
Advertising Contact
Soben Pin
Cell: 979-656-8141
sobenpin@khmerpost.us

អ្នកនិពន្ធកិត្តិយស Staff Writer| Translator
Sokharath Koy

ច្នៃសោភ័ណ្ឌភាព Design Artist
Heng Chhun Leng

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

**AccuCare**
Home Care Agency
Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរា ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មាសហែលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក២៤ម៉ោង

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# LCCPS

LOWELL COMMUNITY CHARTER PUBLIC SCHOOL



ACHIEVEMENT • LEADERSHIP • EXCELLENCE



No Tuition - *We are a Public School!*
Support for ELL & Special Needs
Extended School Day & Year
Gifted & Talented Program
Extended Day Program

Info Session:
January 17th @5:30PM
February 5th @9:00 AM

APPLY ONLINE TODAY!

NOW ACCEPTING APPLICATIONS! 2019-2020

206 Jackson Street • Lowell MA 01852 • (978) 323-0800 • www.lccps.org

# MARCOTTE LAW FIRM

## ក្រុមហ៊ុនមេធាវី Marcotte

45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្ដីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្ដឹងវិវាទទូទៅ
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលទ្រព្យ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទ
មកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ

(978) 458-1229

www.marcottelawfirm.com



# CONWAY

INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវ៉េយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។

**យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :**

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បៈ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វើកខឺម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការលក់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com

សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

ដោយសារតែ

# Health Connector

មនុស្សរាប់ពាន់នាក់ស្វែងរកផែនការណ៍ធានារ៉ាប់រងសុខភាពសំបូរបែបក្នុងតម្លៃទាប ឬឥតគិតថ្លៃ

## អ្នកមានការធានា!



MASSACHUSETTS
HEALTH
CONNECTOR
យើងខ្ញុំភ្ជាប់ទំនាក់ទំនងអ្នកទៅនឹងការថែទាំសុខភាពរបស់អ្នក!

ការចុះឈ្មោះបើកទូលាយនឹងបញ្ចប់ថ្ងៃទី២៣ ខែមករា ហើយគឺជាពេលវេលាប្រចាំឆ្នាំដែលត្រូវធានារ៉ាប់រងសុខភាព ឬទិញផែនការថ្មីមួយសម្រាប់ឆ្នាំបន្ទាប់

### ការធានារ៉ាប់រងដែលមានគុណភាពខ្ពស់

ផែនការសុខភាពរបស់ Health Connector ទាំងអស់រ៉ាប់រងលើអត្ថប្រជន៍សំខាន់ៗ ដែលរួមមាន៖

- ការជួបពិនិត្យជាមួយវេជ្ជបណ្ឌិត
- ការចូលសំរាកព្យាបាលនៅមន្ទីរពេទ្យ
- ការថែទាំពេលមានផ្ទៃពោះនិងទារកទើបនឹងកើត
- សេវាសង្គ្រោះបន្ទាន់
- ការប្រើប្រាស់ឱសថតាមវេជ្ជបញ្ជា
- សេវាស្តារនិតិសម្បទាឡើងវិញ
- ការធ្វើតេស្តនៅមន្ទីរពិសោធន៍
- ការព្យាបាលបង្ការនិងសុខមាលភាព
- សុខភាពផ្លូវចិត្តនិងការប្រើប្រាស់គ្រឿងញៀន

ត្រូវការជំនួយក្នុងការចុះឈ្មោះ? សូមទៅកាន់មជ្ឈមណ្ឌលក្នុងតំបន់របស់អ្នក៖

Boston
133 Portland Street
Boston, MA 02114

ចូលមើល www.MAhealthconnector.org ឬទូរស័ព្ទទៅលេខ: 1-877-623-6765 | TTY 1-877-623-7773



# ការិយាល័យច្បាប់

## រ៉ូសា និង តាំង



Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រ៉ូសា



Andrew 'Bunna' Taing, Esq.
មេធាវី អែន ទ្រូវប៊ុណ្ណា តាំង

Law Office of
**Rosa & Taing**
ATTORNEY AT LAW

| SERVICES | តំណាងក្តីដូចខាងក្រោម |
|---|---|
| Auto Accidents/ Personal Injury | គ្រោះថ្នាក់រថយន្ត/ របួសរូបរាង្គកាយ |
| Bankruptcy | ក្ស័យធន |
| Immigration | អន្តោប្រវេសន៍ |
| Consumer Protection | ការពារអតិថិជន |
| Real Estate Closings/Disputes | ទំនាស់វត្ថុអចលនវត្ថុ |
| Divorces Child Custody | លែងលះ និងអាណាព្យាបាលកិច្ច |

1550 Middlesex Street Lowell, MA 01851
Phone: **978-458-0934** | at@rosataing.com



LEGEND
# MOTOR GROUP, INC.

## ហាងជួសជុលរថយន្ត លេជេន

មានសេវាជួលជុលរថយន្តគ្រប់ប្រភេទ
រយន្ត ប៉ះ បុក ខូចខាត និងក្រពិតមែន រឺទេ?

**ទូរស័ព្ទ 978-458-2085**

COLLISION REPAIR

BEEN IN AN ACCIDENT?
FROM DENTS TO TOTALED,
WE CAN FIX IT ALL.



យើងរៀបចំសណ្តោងរថយន្ត នៅពេលត្រូវការ, ធ្វើការជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រងរបស់លោកអ្នកនិងរៀបចំរាល់ឯកសារទាំងអស់ ។
ការពេញចិត្តរបស់លោកអ្នក គឺជាអាជីវកម្មរបស់យើង ។

**115 Rock St. Unt #7 Lowell, MA 01854**

តមកពីទំព័រទី ០៣

## ទស្សនាក្រុង"ញូយ៉ក"១ថ្ងៃនាចុង...

នេះដោយសារមេត្រូបារាំងមិនលាន់ឮសូរខ្ទ័រត្រចៀកខ្លាំងនោះទេ ហើយក៏រត់លឿនជាងមេត្រូអាមេរិកាំងទៀតផង។ ចេញពី "មេត្រូ"យើងបាននាំគ្នាដើរកាត់ដំបន់សំខាន់ៗមានផ្លូវ"សេនត្រល់ផាក-Central Park" រួចមក ដល់"គ្រោនស្ទេរ៉ូ" ដោយមិនដឹងខ្លួន ពីព្រោះអ្វីៗបានសង់ថ្មីរួចទៅហើយ គេមានទុករូបសិល្បៈ ដូចជាសំណល់នៃផ្ទះទើបនឹងបាក់បែកជាប់គ្នានឹង "អាគារអេះមេយ" ដ៏ខ្ពស់ពណ៌កញ្ចក់ ដែលជាជម្រកនៃ"អង់តែន"ទូរទស្សន៍ដ៏ខ្ពស់ជាងគេទាំងអស់ ក៏បានត្រឡប់មកនៅកន្លែងដដែលវិញ ដូចកាលពីមុនពេលអាគារភ្លោះបានដួលរលំ គួរឱ្យស្ញប់ស្ញែងពេកណាស់។ មានភោជនីយដ្ឋានធំតូចថ្មីស្រស់ស្អាត, មានហាងលក់វត្ថុអនុស្សាវរីយ៍,មានហាងសំលៀកបំពាក់ស្រីប្រុស (ប្អូនប្រុសដែលទទួលឱ្យផ្ទះខ្ញុំសំណាក់ គេជាអ្នកលក់សំលៀកបំពាក់តម្លៃមធ្យមដែលមានតម្លៃយ៉ាងតិច៥០០ឡើងទៅ ក្នុងខោឬក៏អាវ១ កាលពីមុនគេជាអ្នកឯកទេសខាងលក់សំលៀកបំពាក់ស្ត្រីដែលមានតម្លៃខ្ពស់ "ខោក្នុង"១តម្លៃ២-៣ពាន់ដុល្លា)... ភាគច្រើនមានជនជាតិស្បែកខ្មៅជាម្ចាស់ ឬជាអ្នកធ្វើការ គឺជាកន្លែងដ៏អ៊ូអរខ្លាំងណាស់ លក់អ្វីក៏ដាច់ដែរ ពាណិជ្ជករមិនអាចមានពេលទំនេរបានទេ! ដូច្នេះបើមិនប្រាប់ក៏គង់តែគេដឹងថា "ជាទីក្រុងដែលប្រជុំដោយលុយ, សម្បូរការងារធ្វើ, សម្បូរដោយគំនិតឆ្នៃប្រឌិត,



សម្បូររង្គសាលឬកន្លែងកំសាន្ត,...គឺជាឋានសួគ៌លោកីយ ក៏ដូចជាឋាននរកបានដែរ... ប៉ុន្តែប៉ូលីសដ៏ច្រើននៅទីនោះ សម្រាប់បង្ក្រាបអបាយមុខនឹងអំពើទុច្ចរិត កើតដោយការលោភលន់ហួសហេតុដែរ។

ដោយពេលវេលាតិច យើងចូលហាង"ហ្វាសហ្វូត Fastfood" ដែលកន្ទុយរង់ចាំតិច ហើយហូប"ពិតស្ហា Pizza"ម្នាក់១ដុំ ទឹក១កែវជាការស្រេច មុននឹងប្រញាប់ចេញដំណើរទៅមើល"លោកស្រីសេរីភាព Lady Liberty" គឺជារូបចម្លាក់ដ៏ល្បីល្បាញរបស់ស្ត្រីលើកគុបភ្លើងឋិតនៅចំមាត់ទ្វារសមុទ្រនៃក្រុងញូយ៉កតែម្តង។ យើងបានជិះ "សាឡាង Ferry"ឆ្លងទៅកោះ"Staten Island"ដោយមិនចាំបាច់បង់លុយទៅកាន់ក្បែររូបចម្លាក់"សេរីភាព"នោះ តែថតរូបមិនបានល្អទេ ដោយមេឃស្រទំរហ័សពេក ទើបតែ ម៉ោង៤សោះ ព្រះអាទិត្យក៏ផ្តើមលិចទៅហើយ តែពន្លឺភ្លើង នារាត្រីញូយ៉កមើលពីចម្ងាយ ក៏មិនអន់ដែរទេ។



កំពង់ចម្លងទៅកោះ

ជិះសាឡាង១ម៉ោង ទាំងទៅទាំងមកធ្វើឱ្យយើងសម្រាកកាយនឹងខ្យល់រំភើយសមុទ្របានបន្តិចដែរ - មកដល់កំពុងផែ នៅម៉ោង៥ល្ងាច យើងនៅពេលទៅទិញរកសំបុត្រមើលល្ខោននៅ "ប្រដវេយ-Broadway"ដែលសម្បូរទៅដោយការសម្តែងរឿងល្បីៗ តែត្រូវ ទៅទិញសំបុត្រនៅ "ថាមស្គែរ-Time Squere" ទីនោះសម្បូរផ្ទាំងដោយកញ្ចក់ទូរទស្សន៍ធំៗ សម្រាប់តាំងពិពណ៌ ៦ពាណិជ្ជកម្ម ហើយក៏មានលក់សំបុត្រកុនឬល្ខោនតម្លៃថោក នៅ-ទីនោះដែរ... គឺមានមួយកន្លែងតម្លៃ៦៧ដុល្លា ដែលធម្មតានៅឯរោង គេលក់តម្លៃ១៥០ដុល្លា ឯណោះ -ល្ខោននោះមានឈ្មោះថា "សាលា រ៉ក-Rock School"។"សាលាបង្រៀនរបាំរ៉ក"គឺជារឿងល្ខោនប្រភេទ"ល្ខោនចម្រៀង" ដែលតួសម្តែងច្រើនតែក្មេងជារឿងដែលនិយាយពីសាលារៀនដ៏មានវិន័យតឹងតែងមួយក្នុងនោះមាន"គ្រូភ្លេងជំនួស"មកបង្រៀនវិញ្ញាសារ "រ៉កខេន រ៉ល"នៅ ថ្នាក់មួយ... រឿងសម្តែងដោយក្រុមកុមារយ៉ាងចំណានជាមួយនាដករ នាដការីដ៏ជំនាញខាងសិល្បៈសាច់រឿងធ្វើឱ្យក៏ចង់សើចចង់ទប់ក៏ មិនបាន! ហើយបានធ្វើឱ្យអេដែនផ្ទុះសំណើចគ្មានឈប់ ហើយបានធ្វើឱ្យអ្នកមើលឯទៀតៗ ទះដៃអបអរច្រើនដងផង។ នេះជាលើកដំបូងហើយ ដែលកូនស្រីធំរបស់ខ្ញុំចង់ឱ្យឪពុកគេ នឹងប្អូនប្រុសពៅគេបានមើល"ល្ខោននៅប្រដវេយ"ដ៏ល្បីល្បាញលោះពិភពលោកបានម្តង - ជាការពិត គេធ្វើបានល្អមែន!។ ល្ខោនបានសម្តែងចប់នៅម៉ោង១០យប់ តែ"ថាមស្គែរ"នឹង"ប្រដវេយ"នៅតែមានមនុស្សច្រើនអ៊ូអរ, ណែនណាន់តាន់តាប់, នឹងពន្លឺភ្លើពណ៌ ព្រោងព្រាតនៅឡើយ ទោះជាយប់ជ្រៅជាងនេះ ក៏ដោយ។



រោងល្ខោននៅប្រដវេ

ម៉ោង១០យប់ជ្រៅ ណាស់ទៅហើយសម្រាប់ក្មេងៗ យើងមិនទាន់ហូបអ្វីនៅឡើយ ប្អូនប្រុសឈ្មោះ"ទីតូ"ដែលរស់នៅញូយ៉ក ក៏អញ្ជើញយើងទៅហូបបាយល្ងាចនៅជាន់ទី៨ នៃសណ្ឋាគារដ៏ប្រណិតមួយនៅក្បែរគ្នានឹង"ថែមស្គែរ", អេដែនសម្លឹងមើលអ្នកបំរើស្លាបមាន់ចៀន មិនដាក់ភ្នែកទំនងជាឃ្លានខ្លាំង គេបានបញ្ជាយកស្លាបមាន់ចៀននោះមួយចានធំ មនុស្សធំរវល់និយាយគ្នា បញ្ជាភេសជ្ជៈ នឹង"សងវិច"ម្នាក់១ជាការស្រេចសម្រាប់ល្ងាចនេះ ពីព្រោះយប់យឺតពេលបន្តិចហើយដែរ។

ស្អែកឡើង នាម៉ោង១០, ៣០ព្រឹក យើងត្រឡប់ទៅជិះឡាន ប៊ីះ"ឆាយណាថោន"ដើម្បីត្រឡប់មកបូស្តុនវិញ ជិះឡានប៊ីះបណ្តើរ ឱ្យអេដែន ធ្វើមេរៀនបណ្តើរ យើងជជែកគ្នារហូតតាមផ្លូវ នៅពេលដែលរថប៊ីះ បើកជ្រែកទឹកភ្លៀងដែលធ្លាក់មិនឈប់ឈរ នាថ្ងៃអាទិត្យនេះ មិន


ក្រោណសេរ៉ូទើបសង់ថ្មី

អនុញ្ញាតឱ្យមើលទេសភាពត្រកាល តាមផ្លូវបានទេ។ មធ្យោបាយធ្វើដំណើរតាមរថយន្តប៊ីះ ជាបទពិសោធន៍ធ្វើដំណើរមុនពេលចូលឆ្នាំថ្មី ស្រួលខ្លួនគ្រាន់បើដែរ ដែលខ្ញុំនឹងធ្វើដំណើររបៀបនេះ នៅថ្ងៃក្រោយទៀត។

# សហរដ្ឋនាចុងឆ្នាំ២០១៨ប្រកបដោយព្រឹត្តិការភ្ញាក់ផ្អើល

ដោយ ពិន សំខុន

លោកប្រធានាធិបតីអាមេរិកាំង ឌុណល ត្រុម ប្រឈមមុខនឹងការចោទប្រកាន់បទឧក្រិដ្ឋកាន់តែច្រើនឡើង ស្របគ្នានឹងគណបក្សប្រជាធិបតេយ្យក៏ត្រៀមមកចូលកាន់ដំណែងជាគណបក្សភាគច្រើននៅសភាដំណាងរាស្ត្រ នាដើមខែមករា ២០១៩ ថែមទៀតនោះទាំងនេះនឹងគូសវាសទេសភាពនយោបាយអាមេរិកាំងដែលនឹងត្រូវប្រែប្រួល ចាប់តាំងពីខែ ក្រោយនេះទៅហើយ រហូតដល់ចប់អាណត្តិប្តធានាធិបតី។

តាំងតែពីដើមទី នាឱកាសឃោសនា២០១៦ របស់លោក ត្រុម មានជាប់ករណីឧក្រិដ្ឋ២រួចទៅហើយ ដែលបានផ្តើមឡើង គឺករណីលុយឃោសនាពុករលួយ នឹងទំនាក់ទំនងឃោសនាសម្ងាត់ជាមួយពួករុស្ស៊ី ដែលមានយ៉ាងហោចណាស់ ក៏ទាក់ទងនឹងសហការី១៦នាក់ដែលនៅក្បែរលោក"ត្រុម"ដែរ នេះបើតាមសេចក្តីរាយការរបស់ CNN នាពេលថ្មីៗនេះ។ នៅមានករណីជាច្រើនទៀត ដែលកំពុងតែត្រូវគណកម្មការសភាដេញដោលរកការពិតពីសមាជិករដ្ឋាភិបាលពីក្រុមសម្ងាត់ FBI មានខ្លះជំនិតរបស់លោក ត្រុម នោះ ផ្តើមមានពិរុទ្ធទៅហើយ ដោយធ្លាប់បាននិយាយកុហកគណកម្មការស៊ើបអង្កេត ហើយថ្មីៗនេះ លោក "EFlisun"រដ្ឋលេខាធិការកិច្ចការបរទេសដែលទើបនឹងបណ្តេញចេញពីដំណែងបាននិយាយប្រាប់អ្នកសារព័ត៌មានថា "លោក ត្រុម បានបង្ខំលោកឱ្យធ្វើបំពានច្បាប់"...។ ក្នុងពាក់កណ្តាលអាណត្តិនៃប្រធានាធិបតីត្រុមនេះ មានការសម្រេចបទបញ្ជាជាច្រើនដែលផ្ទុយនឹងឆន្ទៈរបស់សមាជិកគណបក្សរបស់លោកផ្ទាល់តែម្តងគ្រួសារលោកប្រធានាធិបតីប៊ូសបានឱ្យដឹងថា"បានបោះឆ្នោតឱ្យ ហ៊ីឡារី គ្លីងតុនឯណោះទេ" រីឯបុណ្យសពលោកព្រឹទ្ធសមាជិកវិរបុរស"ម៉ាកកេន" ក៏មិនបានអញ្ជើញលោក ត្រុម ទៅជាកិត្តិយសដែរ។ លោក ត្រុម ជាប្រធានាធិបតីដែលប្រើមនុស្សចុះជាទីបំផុត, លោក ខេលី នាយកសេតវិមាន ក៏នឹងចាកចេញពីដំណែងនៅចុងឆ្នាំនេះដែរ ហើយពុំទាន់មាននរណាចង់ទៅជំនួស កន្លែងនោះទៀតផង។

ថ្មីៗនេះខាងគណបក្សប្រជាធិបតេយ្យបានបញ្ចេញសម្លេងថា"លោកត្រុមនៅពេលអស់អំណាចនឹងជាប់គុកជាមិនខាន"ដោយសារធ្វើខុសច្រើនពេក។


ប្រធានាធិបតី ដណាល ត្រុម

# SEE VICHET CHUM AS AN ENGLISH LORD IN CHRISTMAS AT PEMBERLEY!

NOW – DEC 23

## MISS BENNET: CHRISTMAS AT PEMBERLEY

BY Lauren Gunderson *(Silent Sky, I and You)* and Margot Melcon

DIRECTED BY Sean Daniels

Vichet Chum, writer and performer of last sesson's *KYNUM*, stars as a wealthy scholar who longs for the perfect wife in this sparkling comedy, a sequel to Jane Austen's *Pride and Prejudice.*


VICHET CHUM

"**DELICIOUS**. . . highly entertaining, the kind of thing multiple generations can enjoy together." -CHICAGO TRIBUNE

**$10 OFF**
*LIMITED SEATS!*

**BOOK NOW**
AT 978-654-4678
OR MRT.ORG

USE PROMO CODE
**CELEBRATE**

**STUDENTS TICKETS $15**


Artwork by Chris Holden

*DISCOUNTS: Use code CELEBRATE for $10 off tickets. $10 discount not valid on SuperSaver seats. Valid only for performances through Dec. 16, limited availability at this rate. Show recommended for ages 10 and up. Discount cannot be combined with other offers. No refunds, no exchanges, all sales final. Adult students, ID required.

circlehealth Complete connected care
SEASON SPONSOR

Lupoli COMPANIES
PRODUCTION SPONSOR

merrimack valley magazine
90.9 wbur
MEDIA SPONSOR

MRT MERRIMACK REPERTORY THEATRE
LOWELL, MA | MRT.ORG